# សេចក្តីជូនដំណឹងស្តីពីការប្រកាសជ្រើសរើស
# អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) សម្រាប់
# គម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតតូច

| | |
|---|---|
| លេខគម្រោង | Project ID: 00093204 |
| ឈ្មោះគម្រោង | គម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពអាទិភាព (SRL) នៃលេខាធិកាដ្ឋាន គ.ជ.អ.ប |
| មុខតំណែងជ្រើសរើស | អ្នកផ្តល់សេវាបច្ចេកទេសឯកជន (TSC) សម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ |
| រយៈពេលផ្តល់សេវា | *ចាប់ពី ១២-១៥ ខែ (ផ្តល់សេវាបច្ចេកទេសរហូតចប់ការអនុវត្ត100%)* |

## ១. សាវតាគម្រោង

យោងឯកសារគម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាម រយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពអាទិភាព (SRL) ដើម្បីអនុវត្តសកម្មភាពកសាងហេដ្ឋារចនាសម្ព័ន្ធដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដូចដែលមាននៅក្នុងផែនការសកម្មភាព និងថវិកាឆ្នាំ២០១៩ ក្នុងគោលបំណងរួមចំណែកកែលម្អជីវភាពរបស់ប្រជាពលរដ្ឋនៅក្នុងខេត្តគោលដៅចំនួនពីរគឺខេត្តសៀមរាប និងខេត្តកំពង់ធំ។ គម្រោង SRL គាំទ្រ និងអនុវត្តលើគម្រោងវិនិយោគសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតតូចដែលធន់នឹងការប្រែប្រួលអាកាសធាតុ ដែលតម្រូវឱ្យប្រើប្រាស់សេវាបច្ចេកទេសឯកជនក្នុងការផ្តល់លើការសិក្សាបច្ចេកទេស រៀបចំគំនូសប្លង់បច្ចេកទេស គណនាតម្លៃប៉ាន់ស្មាន កិច្ចលទ្ធកម្ម និងការអនុវត្តគម្រោងវិនិយោគឆ្នាំ២០១៩។

គម្រោងនឹងផ្តល់បន្ថែមនូវមូលនិធិសម្រាប់ការអភិវឌ្ឍ ចូលរួមចំណែកជាមួយមូលនិធិវិនិយោគឃុំក្នុងគោលបំណងកែលម្អហេដ្ឋារចនាសម្ព័ន្ធជនបទ ដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងដើម្បីគាំទ្រដល់ផលិតភាពកសិកម្មតំបន់ដែលងាយរងគ្រោះក្នុងកម្មវិធីវិនិយោគឃុំ។ ជាទូទៅគម្រោងSRLនឹងបែងចែកថវិកាគាំទ្រជាបីផ្នែកគឺៈ ១) ថវិកាសម្រាប់វិនិយោគចំនួន៨៥% ២) ថវិកា៣%នឹងត្រូវវិភាជន៍សម្រាប់ចំណាយទៅលើកិច្ចការរដ្ឋបាល និងការគាំទ្រអនុវត្តគម្រោងនៅថ្នាក់ស្រុក និង៣) ថវិកា១២%នឹងត្រូវបានប្រើប្រាស់សម្រាប់ជួលអ្នកផ្តល់សេវាបច្ចេក- ទេសឯកជន ឬវិស្វករជាដើម្បីក្នុងជួយក្រុមប្រឹក្សាឃុំក្នុងការរៀបចំការសិក្សាបច្ចេកទេស រៀបចំគំនូសប្លង់បច្ចេកទេស គណនាតម្លៃប៉ាន់ស្មាន កិច្ចលទ្ធកម្ម និងការអនុវត្តគម្រោង ការងារសាងសង់គម្រោង។

ដើម្បីធានាគុណភាពនៃការផ្តល់សេវាបច្ចេកទេសក្នុងការគាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ គម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃជីវភាពរបស់ប្រជាជនកម្ពុជា នៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពអាទិភាព (SRL) នៃលេខាធិកាដ្ឋាន គ. ជ.អ.ប នឹងប្រើប្រាស់ថវិកាមួយចំនួនដើម្បីជ្រើសរើសអ្នកផ្តល់សេវាបច្ចេកទេសឯកជន ដើម្បីជួយក្រុមប្រឹក្សាឃុំ ក្នុងការសិក្សា គ្រោងការគម្រោងនិងតាមដានត្រួតពិនិត្យគម្រោងសម្រាប់ជំនួសឱ្យអ្នកជំនួយការបច្ចេកទេសដែលកំពុងជួយឃុំនាពេលបច្ចុប្បន្ន។

## ២. គោលបំណងនៃការផ្តល់សេវាបច្ចេកទេស

គោលបំណងនៃការផ្តល់សេវាបច្ចេកទេស[1] គឺជាការផ្តល់ឱ្យក្រុមប្រឹក្សាឃុំ នូវសេវាបច្ចេកទេសប្រកបដោយគុណភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធទឹកខ្នាតតូចដែលធន់នឹងការប្រែប្រួលអាកាសធាតុ។ តម្រូវការផ្តល់សេវាបច្ចេកទេសនេះរួមមាន **ការប្រមូលទិន្នន័យព័ត៌មាននៅមូលដ្ឋាន សិក្សាលទ្ធភាពគម្រោង គ្រោងការគម្រោង ប៉ាន់ស្មានតម្លៃគម្រោង**

[1] ដូចបានពិពណ៌នាក្នុងសៀវភៅ គឺម ការផ្តល់សេវាទាំងនេះរួមបញ្ចូលទាំងការពិនិត្យមើលកិច្ចការពារសុវត្ថិភាពបរិស្ថាន ដីធ្លី និងជនជាតិដើមភាគតិច ប៉ុន្តែការពិនិត្យមើលផ្នែកនេះមិនបានដាក់បញ្ចូលទៅក្នុងការងារផ្តល់សេវាបច្ចេកទេសឯកជននេះទេ។

រៀបចំឯកសារដេញថ្លៃ គាំទ្រដំណើរការដេញថ្លៃ និងត្រួតពិនិត្យការអនុវត្តកិច្ច សន្យា។ល។ គម្រោងនឹងត្រូវសាងសង់ដោយអ្នកទទួលការ(អ្នកម៉ៅការ) និងតាមដានការអនុវត្តកិច្ចសន្យាដោយគណៈកម្មការគ្រប់គ្រងគម្រោង តាមរយៈការគាំទ្រហិរញ្ញវត្ថុដោយគម្រោងការកាត់បន្ថយភាពងាយរងគ្រោះនៃ ជីវភាពរបស់ប្រជាជនកម្ពុជានៅជនបទតាមរយៈការពង្រឹងផែនការប្រែប្រួលអាកាសធាតុនៅថ្នាក់ក្រោមជាតិ និងការអនុវត្តសកម្មភាពអាទិភាព (SRL)។

## ៣. ទីតាំង រយៈពេល និងពេលវេលានៃការផ្តល់សេវាបច្ចេកទេស

អ្នកផ្តល់សេវាបច្ចេកទេសឯកជន នឹងត្រូវជ្រើសរើសតាមរយៈកិច្ចសន្យាដាច់ពីគ្នា នៅតាមស្រុកគោលដៅនីមួយៗដើម្បីផ្តល់សេវាបច្ចេកទេសពីការសិក្សាគម្រោងរហូតបញ្ចប់ការអនុវត្តគម្រោង។ កិច្ចសន្យាផ្តល់សេវាបច្ចេកទេស និងបន្ទុកការងារមានសង្ខេបនៅក្នុងតារាងដូចខាងក្រោម៖

| ល.រ | ស្រុកគោលដៅ | ឃុំគោលដៅ | ឈ្មោះគម្រោង | ចំនួន TSC |
|---|---|---|---|---|
| ១ | ប្រាសាទបល្ល័ង្គ | សាគ្រាម | ជួសជុលទំនប់ទឹក និងទ្វារទឹក | ១ នាក់ |
| | | សាមគ្គី | សាងសង់អណ្តូងលូ ដាក់ស្នប់រ៉ៃ | |
| | | ផាន់ញើម | ជួសជុលទំនប់ទឹក និងទ្វារទឹក | |
| | | ក្រយា | ជួសជុលទំនប់ និងទ្វារទឹក | |

## ៣. តម្រូវការលក្ខណៈសម្បត្តិ និងបទពិសោធន៍

ក្នុងពេលដំណើរការការងារ អ្នកផ្តល់សេវាបច្ចេកទេសឯកជដែលមកពីផ្នែកឯកជន នឹងមិនរំពឹងថាទទួលបានការណែនាំច្រើនអំពីដំណើរការណែនាំពីការអនុវត្តគម្រោងមូលនិធិឃុំ(PIM) និងសៀវភៅណែនាំបច្ចេកទេសរបស់ គ.ជ.អ.ប ឡើយ។ ដូច្នេះ ក្នុងកំឡុងពេលចាប់ផ្តើមដំណាក់កាលនីមួយៗនៃការសិក្សាលទ្ធភាពគម្រោង រៀបចំគម្រោង រៀបចំលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់របស់អ្នកទទួលការ អ្នកផ្តល់សេវាបច្ចេកទេសឯកជននឹងទទួលបានការគាំទ្រ និងសម្របសម្រួលពីមន្ត្រីសម្របសម្រួលគម្រោង ទីចាត់ការផែនការ និងវិនិយោគនៅថ្នាក់ខេត្ត និងមន្ត្រីគម្រោង SRL ថ្នាក់ស្រុកលើដំណើរការដែលត្រូវអនុវត្ត។ ដើម្បីមានលទ្ធភាពធ្វើការងារនេះឱ្យមានប្រសិទ្ធភាព បេក្ខជនត្រូវមានសមត្ថភាព និងបទពិសោធន៍ដូចខាងក្រោម៖

- ✓ យ៉ាងហោចណាស់មានកម្រិតជំនាញ ឬសញ្ញាបត្រវិស្វករជាពសាស្រ្តកសិកម្ម សំណង់ស៊ីវិល ឬជំនាញប្រហាក់ប្រហែល
- ✓ មានបទពិសោធន៍យ៉ាងតិច៣ឆ្នាំក្នុងការសិក្សាវាស់ស្ទង់ គ្រោងប្លង់គម្រោង ប៉ាន់ស្មានតម្លៃ ត្រួតពិនិត្យគម្រោងហេដ្ឋារចនាសម្ព័ន្ធជនបទ (ជាពិសេសគម្រោងហេដ្ឋារចនាសម្ព័ន្ធថ្នាក់ឃុំ) ដូចជា ទំនប់ ប្រឡាយ សំណង់ប្រព័ន្ធជាពសាស្រ្តខ្នាតតូច មធ្យម ឬស្រះ។ល។
- ✓ មានចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ និងការយល់ដឹងពីផ្នែកសមភាពយេនឌ័រ
- ✓ ចេះប្រើកុំព្យូទ័រដូចជាកម្មវិធី Word, Excel, AutoCAD និងប្រព័ន្ធអ៊ិនធឺណេត អ៊ីម៉ែល
- ✓ ត្រូវតែស្ថិតនៅ ឬមានឆន្ទៈធ្វើការនៅក្នុងស្រុកគោលដៅ
- ✓ មានសម្ភារៈ ឧបករណ៍សិក្សាបច្ចេកទេស និងមធ្យោបាយធ្វើដំណើរបានញឹកញាប់ទៅតាមឃុំគោលដៅ។

☞ បុគ្គលដែលមានចំណាប់អារម្មណ៍ត្រូវដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV)។ មុនពេលដាក់ពាក្យសូមពិនិត្យមើលលក្ខខណ្ឌការងារសម្រាប់ផ្តល់សេវាបច្ចេកទេសឯកជនដែលអាចរកពីក្រុមការងារកម្មវិធីថ្នាក់ខេត្ត ស្រុក ឬទាញយកបានគេហទំព័រ គ.ជ.អ.ប www.ncdd.gov.kh/jobs and procurement។

☞ ដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV) និងត្រូវបំពេញក្នុងលិខិតស្តីពីការសម្តែងចំណាប់អារម្មណ៍ (ឧបសម្ព័ន្ធ ក.១) ប្រកក្នុងស្រោមសំបុត្រដាក់នៅតាមស្រុក ខេត្តគោលដៅខាងលើតាម រយៈក្រុមការងារកម្មវិធី។ រាល់ការដាក់ពាក្យស្នើសុំមិនអាចផ្ញើតាមអ៊ីម៉ែលបានឡើយ។

| | |
|---|---|
| ☞ កាលបរិច្ឆេទឈប់ទទួលពាក្យនៅម៉ោង៥ និង៣០នាទី ល្ងាច ថ្ងៃទី ១០ ខែ មេសា ឆ្នាំ២០១៩<br>☞ មានតែអ្នកដែលបានជាប់ក្នុងបញ្ជីសម្រាំងខ្លីនៃបេក្ខជន ប៉ុណ្ណោះនឹងត្រូវជូនដំណឹងអំពីការសំភាសន៍។ | |
| សូមទំនាក់ទំនង ព័ត៌មានបន្ថែម | ១.ក. ខេត្តកំពង់ធំ៖ លោកស្រី វ៉ន សុគន្ធារី ទីប្រឹក្សាគម្រោងប្រចាំខេត្តកំពង់ធំ (SRL-NCDDS) ទូរស័ព្ទលេខ៖ 085 884 492<br>អ៊ីមែល៖ sokunthearyvorn@gmail.com<br>១.ខ. ខេត្តសៀមរាប៖ លោក ឈុន សុផល ទីប្រឹក្សាគម្រោងប្រចាំខេត្តសៀមរាប (SRL-NCDDS) ទូរស័ព្ទលេខ៖ 012 921 850<br>អ៊ីមែល៖ chhun.sophal12@gmail.com |
| | ២. លោក ជុំ សុជាតិ មន្ត្រីទទួលបន្ទុកផែនការ និងបញ្ជ្រាបការប្រែប្រួលអាកាសធាតុ (លេខាធិការដ្ឋាន គ.ជ.អ.ប)<br>អ៊ីមែល៖ socheat.chum@ncdd.gov.kh ទូរស័ព្ទលេខ៖ 077 966 698 |

ថ្ងៃអង្គារ ៦រោច ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ប្រាសាទបល្ល័ង្ក, ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០១៩

**អភិបាលស្រុក**

**វណ្ណៈ សោភានិត**